# ចំណាប់អារម្មណ៍របស់ខ្ញុំអំពីការងារស្ម័គ្រចិត្តនៅ
# អង្គការកម្ពុជាសម្រាប់ការរស់នៅ និងការថែទាំបណ្ដោះអាសន្ន (ខូលត៍)

សួស្តី! ខ្ញុំឈ្មោះ ហឿង សុម៉ាលីន។ ខ្ញុំជានិស្សិតឆ្នាំទី៣ នៅវិទ្យាស្ថានជាតិសង្គមកិច្ច ជំនាញសង្គមកិច្ច។ ខ្ញុំបានធ្វើការស្ម័គ្រចិត្តនៅអង្គការខូលត៍តាំងពីថ្ងៃទី១៥ ខែមករា ឆ្នាំ២០២០ រហូតដល់បច្ចុប្បន្ន។ ក្នុងគោលបំណងដើម្បីទទួលបានបទពិសោធន៍ការងារក្នុងជំនាញរបស់ខ្ញុំ ខ្ញុំត្រូវយល់ដឹងអំពីវិធីសាស្ត្រធ្វើការដោយសមស្រប និងប្រកបដោយវិជ្ជាជីវៈជាអ្នកធ្វើការសង្គម តាមរយៈការបង្ហាត់បង្ហាញ និងបណ្តុះបណ្តាលអំពីគ្រូ និងបុគ្គលិកដែលមានបទពិសោធន៍នៅក្នុងអង្គការខូលត៍។

ពេលដែលខ្ញុំបានចាប់ផ្តើមធ្វើការងារស្ម័គ្រចិត្តនៅអង្គការខូលត៍ ខ្ញុំបានទទួលការស្វាគមន៍យ៉ាងកក់ក្តៅ និងទទួលបានចំណេះដឹងយ៉ាងច្រើនពីលោកពិសិដ្ឋ លោករាហ៊ូ និងកញ្ញាគ្រីស្ទីន ដែលពួកគាត់បានបង្រៀនខ្ញុំនូវការងារ និងមេរៀនជាច្រើនដែលរួមមាន៖ ការធ្វើការងារដោយផ្ទាល់ជាមួយអតិថិជនក្នុងសហគមន៍ (ការគ្រប់គ្រងករណី ការតាមដាននិងធ្វើខេសណូត និងការធ្វើផែនការណ៍អន្តរាគមន៍សម្រាប់ជួយដល់គ្រួសារនិងកុមារ) ហើយនិងធ្វើការដោយផ្ទាល់ជាមួយកុមារ។ លើសពីនេះទៀតលោកគ្រូអ្នកនៅទីនេះបានបង្រៀនខ្ញុំឲ្យរៀនសង្កេតអាកប្បកិរិយាកុមារក្នុងពេលដែលពួកគេកំពុងតែសិក្សាដើម្បីបានយល់ដឹងអំពីអាកប្បកិរិយាផ្សេងៗគ្នារបស់កុមារម្នាក់ និងយល់ដឹងអំពីតម្រូវការរបស់កុមារតាមរយៈការប្រឹក្សាយោបល់ផងដែរ មិនត្រឹមតែប៉ុណ្ណោះលោកគ្រូអ្នកគ្រូក៏បានបង្ហាត់បង្រៀនខ្ញុំអំពីកិច្ចការរដ្ឋបាលជាច្រើនទៀតសម្រាប់ការងារសង្គម។

ជារួមចំណេះដឹង និងបទពិសោធការដែលខ្ញុំបានទទួលកន្លងមកនេះគឺពិតជាល្អ ហើយសុទ្ធសឹងជាបទពិសោធដែលខ្ញុំតែងតែចង់ចេះចង់ដឹងពីមុនមក។

ជាចុងក្រោយ ខ្ញុំសូមថ្លែងអំណរគុណចំពោះលោកគ្រូអ្នកគ្រូនៅក្នុងអង្គការខូលត៍ដែលបានស្វាគមន៍ខ្ញុំយ៉ាងកក់ក្តៅមានសណ្តានចិត្តល្អ រាក់ទាក់និងយកចិត្តទុកដាក់ក្នុងការបង្ហាត់បង្រៀនខ្ញុំទាំងកាយទាំងចិត្តនូវបទពិសោធការងារដ៏មានសារៈសំខាន់នេះ។ ខ្ញុំនឹងព្យាយាមអស់ពីកំលាំងការចិត្តក្នុងការងារស្ម័គ្គចិត្តនេះ និងគោរពតាមសេចក្តីណែនាំបន្ថែមទៀតរបស់លោគ្រូអ្នកគ្រូ។

***សូមអរគុណ!***

